Los Angeles County
Registrar-Recorder/County Clerk

ការចុះឈ្មោះអ្នកបោះឆ្នោត

ដើម្បីឱ្យមានលក្ខណសម្បត្តិជាអ្នកបោះឆ្នោតម្នាក់នៅក្នុង រដ្ឋកាលីហ្វ័រញ៉ា លោកអ្នកត្រូវតែចុះឈ្មោះបោះឆ្នោត។ ក្នុងនាមជាអ្នកចុះឈ្មោះបោះឆ្នោតម្នាក់ លោកអ្នកនឹងទទួលព័ត៌មានអំពីការបោះឆ្នោត អំពីបេក្ខជន និងវិធានការនានាដែលមាននៅក្នុងសន្លឹកឆ្នោតរបស់លោកអ្នកនិងព័ត៌មាននៅតាមកន្លែងបោះឆ្នោត មុនពេលបោះឆ្នោតម្តងៗ។ ការបោះឆ្នោតជាមធ្យោបាយមួយដែលងាយស្រួលក្នុងការឱ្យមានសំឡេងក្នុងសង្គមប្រជាធិបតេយ្យរបស់យើង។ ត្រូវឱ្យប្រាកដថាលោកអ្នកចុះឈ្មោះបោះឆ្នោតថ្ងៃនេះ!

ចុះឈ្មោះបោះឆ្នោត ដោយការបំពេញទម្រង់ចុះឈ្មោះបោះឆ្នោត។ ទម្រង់ចុះឈ្មោះបោះឆ្នោតមាននៅតាមបណ្តាញគេហទំព័រ **LAVOTE.net** និងនៅតាមការិយាល័យរដ្ឋមួយចំនួនទៀត ដូចជាបណ្ណាល័យ ឬ DMV។

ការចុះឈ្មោះបោះឆ្នោតគឺអចិន្ត្រៃយ៍។ លោកអ្នកចុះឈ្មោះ តែពេលណាព័ត៌មានលោកអ្នកផ្លាស់ប្តូរ។ ពិនិត្យ*ស្ថានភាពនៃការចុះឈ្មោះ*របស់លោកអ្នក តាមបណ្តាញគេហទំព័រនៅ **LAVOTE.net**។

លោកអ្នក **ត្រូវតែ** *ចុះឈ្មោះបោះឆ្នោតសារជាថ្មី បើសិនជាលោកអ្នកផ្លាស់លំនៅដ្ឋានថ្មី* ដូរឈ្មោះថ្មី ឬដូរគណបក្សនយោបាយអាទិភាពរបស់លោកអ្នក។ លោកអ្នក **មិន** ចាំបាច់ចុះឈ្មោះបោះឆ្នោតសារជាថ្មីទេ បើសិនជា លោកអ្នកអាក់ខានការបោះឆ្នោតណាមួយ។

ចូរចាំ

កាលបរិច្ឆេទត្រូវផុតកំណត់សំរាប់ចុះឈ្មោះបោះឆ្នោតគឺ **15 ថ្ងៃ** **មុនថ្ងៃបោះឆ្នោត**។

- *តើលោកអ្នកជាពលរដ្ឋអាមេរិកាំង ឬ?*
- *តើលោកអ្នកជាគេហជនរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ឬ?*
- *តើលោកអ្នកនឹងមានអាយុ 18 ឆ្នាំ ឬចាស់ជាងនៅថ្ងៃបោះឆ្នោត ឬ?*

បើលោកអ្នកឆ្លើយ "បាទ/ចាស" សំរាប់សំណួរទាំងអស់នោះលោកអ្នកគួរតែចុះឈ្មោះបោះឆ្នោត!

www.LAVOTE.net

ដើម្បីស្នើសុំសម្ភារៈបោះឆ្នោតជាភាសា ចិន ជប៉ុន កូរ៉េ អេស្ប៉ាញ៉ុល តាហ្គាឡុក វៀតណាម ហ៊ីនឌូ ខ្មែរ ឬថៃ សូមទូរស័ព្ទមកយើង 1.800.481.8683 ។

Khmer